# របាយការណ៍
# ស្តីពី
# សកម្មភាពការងារប្រចាំខែ កុម្ភៈ ឆ្នាំ២០១០
# របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
# និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុង ខែកុម្ភៈ ឆ្នាំ២០១០ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដោយមានអគ្គលេខាធិការដ្ឋានជាអង្គភាពប្រតិបត្តិ បានដំណើរការការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម :

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### ក. ការងាររដ្ឋបាល

-ផ្ញើលិខិតលេខ ០០៤/១០ បព ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ស្តីពីការផ្ញើព្រឹត្តប័ត្រ លេខ ០៣ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិ ជូនគ្រប់ក្រសួងស្ថាប័នរដ្ឋ អភិបាលរាជធានី-ខេត្ត សាលាដំបូងរាជធានី-ខេត្ត អង្គការក្រៅរដ្ឋាភិបាល ស្ថានទូត

-ផ្ញើលិខិតលេខ ០០៥/១០ លស.កកចយ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១០ ជូនឯកឧត្តមអគ្គលេខាធិការរងរាជរដ្ឋាភិបាលនៃទីស្តីការគណៈរដ្ឋន្ត្រី សំណើសុំបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់ថ្នាក់ដឹកនាំ ប្រធានផ្នែក អនុប្រធានផ្នែក ដើម្បីចុះទៅធ្វើការណែនាំលើផែនការកំណែទម្រង់ច្បាប់ និងតុលាការនៅសាលាដំបូងខេត្តកំពង់ធំ សៀមរាប បន្ទាយមានជ័យ និងបាត់ដំបង

-ផ្ញើលិខិតលេខ ០០៦/១០ លស.កកចយ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០ ជូនឯកឧត្តមអគ្គលេខាធិការរងរាជរដ្ឋាភិបាលនៃទីស្តីការគណៈរដ្ឋន្ត្រី សំណើសុំបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់ប្រធានផ្នែក អនុប្រធានផ្នែក ដើម្បីទៅចូលរួមសិក្ខាសាលាស្តីពីការបណ្តុះបណ្តុះបណ្តាលមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សានៅខេត្តបាត់ដំបង

-ផ្ញើលិខិតលេខ ០០៧/១០ លអ.កកចយ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ អញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ(TWG/LJR)នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១០

-ផ្ញើលិខិតលេខ ០០៨/១០ លអ.កកចយ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ សំណើអញ្ជើញគណៈប្រតិភូដែលបានអញ្ជើញទៅចូលរួមទស្សនៈកិច្ចសិក្សានៅប្រទេសកូរ៉េ ចូលរួមសិក្ខាសាលាស្តីពីការបញ្ចប់របាយការណ៍អំប៊ូស្មាន់(Ombudsman)

-ផ្ញើលិខិតលេខ ០១០/១០ លស.កកចយ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១០ សំណើសុំចាត់តាំងអ្នកតំណាង ០១ រូប ចូលរួមប្រជុំពិនិត្យលើការអនុវត្តកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី០២ ខែមិនា ឆ្នាំ២០១០

-ផ្ញើលិខិតលេខ ០១១/១០ លស.កកចយ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០ សំណើសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់ថ្នាក់ដឹកនាំ ប្រធានផ្នែក អនុប្រធានផ្នែក និងមន្ត្រីអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីចុះទៅធ្វើផែនការយុទ្ធសាស្រ្ត នៅខេត្តព្រះសីហនុ

-ទទួលលិខិតលេខ ៣៧ លអជ.រប ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១០ អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខារវាង Universite de Palerme ជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈព្រមទាំងអាជ្ញាធរអប្សរាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១០ នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលលិខិតលេខ០១៥ លអជ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១០ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំលើកទី ០៦ របស់ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងជំនួយផ្នែកច្បាប់ព្រហ្មទណ្ឌ និងយុត្តនៅកម្ពុជានៅ Imperial Garden Hotel

-ទទួលិខិតលេខ ១៤១/១០ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២១០១ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំណើចូលរួមកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសចម្រុះ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ទទួលលិខិតលេខ ៤៨ លអជ.រប ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០ អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០

-ទទួលលិខិតលេខ ១៤៦/១០ កអក/គជនា ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំណើអញ្ជើញចូលរួមកិច្ចប្រជុំដើម្បីពិភាក្សាលើសេចក្តីព្រាងរបៀបវារៈរបស់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើទី ៣ (3rd CDCF)

-ទទួលលិខិតលេខ ០៦/១០ គជបអ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ពីគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍន៍ សំណើអញ្ជើញចូលរួមសិក្ខាសាលា ស្តីពីផលប៉ះពាល់នៃការប្រែប្រួលរចនាសម្ព័ន្ធអាយុទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនៅកម្ពុជា នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលលិខិតលេខ ៥១/១០ លអជ.រប ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកមហោស្រពសិល្បៈល្ខោននាដកម្មខ្មែរទូទាំងប្រទេសដើម្បីអបអរសាទរទិវាវប្បធម៌ជាតិ ៣មីនា ឆ្នាំ២០១០ (លើកទី១២ ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្ត សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋន្ត្រី និងលោកជំទាវ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១០ នៅសាលសន្និសីទចតុមុខ

-ទទួលលិខិតលេខ ២៣៤/១០កយអជច ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០ ពីក្រសួងយុត្តិធមិ សំណើអញ្ជើញមន្ត្រីនៃអគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ ចំនួន ០១រូប ចូលរួមសន្និសីទជាតិដើម្បីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌ

-ទទួលលិខិតលេខ ១៨៥ DIP/NGOF ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ពីអង្គការសម្ព័ន្ធដើម្បីសុរិច និងគណនេយ្យភាពសង្គម សំណើសុំដាក់បញ្ចូលនូវមតិយោបល់របស់អង្គការមិនមែនរដ្ឋាភិបាលទៅលើផ្នែកប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅក្នុងសេចក្តីព្រាងលើកទី១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣

-ទទួលលិខិតលេខ ៥៨ លអជ.រប ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពងខ្ពស់របស់សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈ ១-សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការគាំពា និងអភិវឌ្ឍន៍កុមារតូច ២-សេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីបណ្តឹងទាក់ទងនិងឋានៈបុគ្គល ៣-បញ្ហាផ្សេងៗ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលលិខិតលេខ៦៤ លអជ.រប ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១០ ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោអាគារសិក្សាថ្មីរបស់ វិទ្យាស្ថានសន្តប៉ូល (អតីតវិទ្យាស្ថានឯកទេសកសិកម្មសន្តប្រូង់ស្វ័រ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលប្រព្រឹត្តទៅនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ នៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ

-ទទួលលិខិតលេខ ៨៦ លអជ.រប ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ចូលរួមប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០

-ទទួលសេចក្តីសម្រេចលេខ ០៦ អយក.សសរ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១០ ពីក្រសួងអប់រំ យុវជន និងកីឡា នូវសេចក្តីសម្រេចស្តីពីការបង្កើតលេខាធិការដ្ឋាន នៃក្រុមការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ ក្រសួងអប់រំ យុវជន និងកីឡា

## ខ. ការងារកំណែទម្រង់

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ បានធ្វើការប្រជុំផ្ទៃក្នុងក្រោម

អធិបតីភាព ឯកឧត្តម ស៊ុយ ម៉ុងលាង អគ្គលេខាធិការ ដើម្បីពិនិត្យនិងពិភាក្សាទៅលើការដាក់ចេញនូវសូចនារសម្រាប់ឆ្នាំ២០១០ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០

-ចូលរួមប្រជុំជាមួយអ្នកជំនាញការ CCJAPIII ដើម្បីពិភាក្សាទៅលើទម្រង់នៃការសរសេររបាយការណ៍ ដើម្បីអោយបានល្អ និងចំទិសដៅ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០

-អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានរៀបចំកិច្ចប្រជុំផ្ទៃក្នុង ក្រោមអធិបតីភាព ឯកឧត្តម សួង លាងហៃ អគ្គលេខាធិការរង ដើម្បីពិនិត្យនិងពិភាក្សាទៅលើការរៀបចំធ្វើសិក្ខាសាលាស្តីពីអំប៉ូស្នាន់នៅកម្ពុជា និងការរៀចំធ្វើបច្ចុប្បន្នកម្មទៅលើផែនការសកម្មភាពទាំង ៩៧ ព្រមទាំងបានធ្វើការពិភាក្សាទៅលើការចុះទៅតាមក្រសួងផ្សេងៗដើម្បីប្រមូលព័ត៌មាន ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១០ នៅទីស្តីការគណៈរដ្ឋមន្ត្រី

-បានចែកផ្សាយនូវព្រឹត្តប័ត្រព័ត៌មានរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ លេខ០៣ឆ្នាំ២០១០

-បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១០

-បានជួបប្រជុំជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីរៀបចំប្រព័ន្ធសូចនាករតាមដានរួម (JMIs) ឆ្នាំ២០១០

### គ. ផ្សេងៗ

-ចូលរួមប្រជុំអន្តរក្រសួង

-បានចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈ ១-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការគាំពា និងអភិវឌ្ឍន៍កុមារតូច ២-សេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីបណ្តឹងទាក់ទងនិងឋានៈបុគ្គល ៣-បញ្ហាផ្សេងៗ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ នៅទីស្តីការគណៈរដ្ឋមន្ត្រី

- ចូលរួមសិក្ខាសាលាស្តីពីការបណ្តុះបណ្តុះបណ្តាលមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សានៅខេត្តបាត់ដំបង រយៈពេលពីរថ្ងៃ

## ២-សន្និដ្ឋាន

ក្នុងខែ កុម្ភៈ ឆ្នាំ២០១០ នេះក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាអង្គភាពប្រតិបត្តិបាន និងកំពុងរៀបចំឯកសារជាមូលដ្ឋានផ្សេងៗដើម្បីរៀបចំសិក្ខាសាលាស្តីពីការបញ្ចប់របាយការណ៍អំប៉ូស្នាន់នៅកម្ពុជា និងស្តីពីការពិនិត្យពិភាក្សាលើការអនុវត្តកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការនៅសណ្ឋាគារអាំងទែរកុងទីណង់តាល់នាដើមខែមីនានេះ។

**៣-ទិសដៅអនុវត្តក្នុងខែមិនា**

-ប្រជុំពិនិត្យសេចក្តីព្រាងកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្ររបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-ប្រជុំពិនិត្យសេចក្តីព្រាងកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការបច្ចុប្បន្នកម្ម ២០១០-២០១៣

-ប្រជុំពិនិត្យសេចក្តីព្រាងសំណើក្របខ័ណ្ឌបញ្ចូលប្រព័ន្ធអំប៊ូដ្សម៉ាន់នៅកម្ពុជា ។

*រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០*

**អ្នកធ្វើរបាយការណ៍**

**បានឃើញ និងឯកភាព**

**អគ្គលេខាធិការ**

**ស៊ុន សិរីវុធ**

**ស៊ុយ ម៉ុងលាង**